ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៨/១១-ជី អេច ជី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ជី អេច ជី (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៧៣៧ ២៦៤ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២ ៖

-លោកស្រី ជា លីជូ រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកម្ពុជា**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ជី អេច ជី**

អាសយដ្ឋាន ៖ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៩៦០ ៨៦០ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១-លោក ស៊ឹម វណ្ណា | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២-លោក ស៊ាង យ៉ូត | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣-លោក មួ ឈាង | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៤-លោកស្រី ស៊ាន សុផល | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ |
| ៥-កញ្ញា ខាត់ សុផល | លេខាធិការសហជីព |
| ៦-កញ្ញា ជា រតនា | សកម្មជន |
| ៧- កញ្ញា ទន់ សុជាតិ | ជំនួយការក្រុមដេរ |

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១-លោក ស៊ាង យ៉ូត | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២-លោក សាន សុផា | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣-លោកស្រី ស៊ាន សុផល | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ |
| ៤-កញ្ញា ខាត់ សុផល | លេខាធិការសហជីព |
| ៥-កញ្ញា ជា រតនា | សកម្មជន |
| ៦-កញ្ញា ទន់ សុជាតិ | ជំនួយការក្រុមដេរ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ជី អេច ជី នៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងតំលៃបុងបន្ថែមចំនួន ០.២០ ដុល្លា ជូនកម្មករនិយោជិតគ្រប់ផ្នែកចំពោះកម្មករស៊ីបុង។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចតម្លើងតំលៃបុងបន្ថែមបានទេ ដោយក្រុមហ៊ុនគ្មានលទ្ធភាព ។

២-ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ជី អេច ជី នៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ចំពោះការថែមម៉ោងដល់ម៉ោង ២០:០០ យប់ ពីលើលុយថ្លៃបាយដែលកន្លងមកក្រុមហ៊ុនផ្តល់ឱ្យចំនួន ២០០០ រៀល និងទាមទារលុយថ្លៃបាយធ្វើការថែមម៉ោងនៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យចំនួន ១០០០ រៀល ក្នុងមួយម៉ោង ព្រោះសព្វថ្ងៃនេះក្រុមហ៊ុនឱ្យកម្មករធ្វើគ្មានផ្តល់លុយថ្លៃបាយឱ្យទេ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់លុយថ្លៃបាយបន្ថែមតាមការទាមទាររបស់បងប្អូនបានទេ ព្រោះក្រុមហ៊ុនគ្មានលទ្ធភាពផ្តល់ជូន ។

៣-ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ជី អេច ជី នៅតែទាមទារឱ្យក្រុមហ៊ុន ជី អេច ជី តម្លើងប្រាក់ឈ្នួលគោលដល់ជំនួយការក្រុមផ្នែកបើកឥវ៉ាន់ចំនួន ៧០ ដុល្លា។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចតម្លើងប្រាក់ឈ្នួលគោលបន្ថែមដល់ជំនួយការក្រុមផ្នែកបើកឥវ៉ាន់បានទេ ព្រោះថា ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលជូនពួកគាត់មិនទាបជាង ៦១ ដុល្លាឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩៤៦ កប/អក/វក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖

- លើកទី១ ៖ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក )។
- លើកទី២ ៖ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ (វេលាម៉ោង ០២:០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី** ៖

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ០៨៧/១១ ស.ប.ក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៩៤៦ ក.ប/អក/វ.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ ចំនួនពីរលើក គឺលើកទី១ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨ ៖៣០ នាទីព្រឹក និងលើកទី២ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ០២ ៖០០ នាទី រសៀល ។

ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួនកន្លះចំណុច គឺចំណុចវិវាទទី២ ត្រង់ចំណុចទាមទារថ្លៃបាយធ្វើការថែមម៉ោងនៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ចំនួន ១០០០ រៀល ហើយនិយោជកក៏យល់ព្រមតាមសំណើរ។

នៅថ្ងៃសវនាការ ភាគីវិវាទបានយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពន្យាថ្ងៃចេញសេចក្តីបង្គាប់ទៅដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សរណៈនៃការយោគយល់ គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នាឱ្យសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សរណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។

ក្នុងករណីនេះ ភាគីវិវាទបានជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើវិវាទអំពីប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក៖

១-លិខិតផ្ទេរសិទ្ធិរបស់នាយករោងចក្រ ជី អេច ជី ជូនលោកស្រី ជា លីជូ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១

២-លិខិតបញ្ជាក់បន្ថែមពីក្រុមហ៊ុន ជី អេច ជី អំពីតំលៃបង់ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ ។

៣-សារណា ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ។

៤-តារាងរាយនាមកម្មករស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ។

៥-តារាងតំលៃបុងរបស់កម្មករ ។

៦-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន អឺ អេច ជី លេខ ៣០៩៦ ៣ណ. ចបព ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ។

៧-បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជី អេច ជី ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ ។

៨-តារាងបើកប្រាក់បៀវត្សសំរាប់ខែ ឧសភា, ខែមិថុនា, ខែកក្កដា ឆ្នាំ២០១១ ។

៨-ពាក្យបណ្តឹងជំទាស់របស់ក្រុមហ៊ុន ជី អេច ជី ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ ។

៩-តារាងតំលៃបុងប្រចាំថ្ងៃរបស់កម្មករឈ្មោះ ប៉ាត ស្រីនាង, ពេជ្រ ស្រីអូន, អ៊ុម គីមឡេង, ពេញ ពឿន, វីធី តា, ឈូក ពុំ ។

១០-បញ្ជីដេរដល់គោលដៅ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១-សារាណលេខ ១១២/១១ សបក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ។

២-លិខិតពឹងពាក់របស់សហជីពស៊ីខៅខ្វ ប្រចាំរោងចក្រ ជី អេច ជី ឱ្យលោកប្រធានសម្ព័ន្ធសហជីព ស៊ីខៅខ្វ ជួយដោះស្រាយនូវចំនុចទាមទារមួយចំនួនរបស់សហជីព ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១

៣-វិញ្ញាបនប័ត្រចុះបញ្ជីការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ជី អេច ជី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ។

៤-សេចក្តីប្រកាសព័ត៌មានរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១១ ។

៥-សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ។

៦-សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០៤១/១១ កប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ។

៧-ស្នាមមេដៃកម្មករនិយោជិតនៃក្រុមហ៊ុន ជី អេច ជី ដែលទាមទារលុយបាយថែមម៉ោង ១៨:០០ ដល់ម៉ោង ២០:០០ នាទី ៣០០០ រៀល និងតម្លើងតម្លៃបុងគ្រប់ផ្នែកចំនួន ០,២០$ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១។

៨-ឈ្មោះជំនួយការបើកឥវ៉ាន់ទាមទារតម្លើងប្រាក់ឈ្នួល ។

៩-របាយការណ៍តំលៃបុងសម្រាប់តុកាត់ ។

១០-តំលៃបុងរបស់កម្មករ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជី អេច ជី លេខ ៩៤៦ កប/អក/វក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ជី អេច ជី ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៦១៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៦១៧ កប/អក/វក/លកអ.ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១១។

៣-លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៦៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១។

៤-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៦៨៨ កប/អក/វក/លកអ.ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១១។

៥-ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ជី អេច ជី (ខេមបូឌា) ជាក្រុមហ៊ុនផលិតសំលៀកបំពាក់។ ក្រុមហ៊ុននេះ បានចាប់ដំណើរការនៅក្នុងឆ្នាំ២០០៣ ដោយមានជួលកម្មករនិយោជិតសរុបចំនួនប្រហែល ១០០០ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះមានសមាជិកចំនួនប្រហែលជា ៥៥០ នាក់ ប៉ុន្តែតាមរយៈការកាត់ប្រាក់ភាគទានសមាជិកសហជីពមានចំនួនប្រហែលជា ២៧៦ នាក់ប៉ុណ្ណោះ។
- នៅក្នុងក្រុមហ៊ុនមានសហជីពតែមួយទេ គឺសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា។ សហជីពនេះពុំទាន់មានភាពជាតំណាងបំផុតនៅឡើយទេ ។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងតម្លៃបុងបន្ថែមចំនួន ០.២០ ដុល្លារអាមេរិក ជូនកម្មករនិយោជិតគ្រប់ផ្នែកទាំងអស់**

- នៅក្នុងក្រុមហ៊ុន មានកម្មករនិយោជិតដែលដេរស៊ីបុងចំនួនជិត ៦០០ នាក់ ដែលនៅក្នុងនោះមានកម្មករនិយោជិតនៅផ្នែកដេរចំនួនប្រហែលជា ៥៥០ នាក់ កម្មករនិយោជិតនៅផ្នែកអ៊ុតមានចំនួន ២ នាក់ និងនៅផ្នែកតុកាត់មានចំនួនប្រហែលជា ២០ នាក់។

- ម៉ោងការងាររបស់កម្មករនិយោជិត គឺចាប់ផ្តើមធ្វើការពីម៉ោង ៧:០០ នាទី ទៅដល់ម៉ោង ១១:០០ នាទី ព្រឹក។ ពេលរសៀលចាប់ផ្តើមចូលពីម៉ោង ១២:០០ ដល់ម៉ោង ៤:០០ នាទី ល្ងាច។ ជាទូទៅនិយោជក តែងតែមានធ្វើការថែមម៉ោងដោយបន្តពីម៉ោង ៤:០០ រហូតដល់ម៉ោង ០៦:០០ នាទីល្ងាច។
- ការគិតប្រាក់ឈ្នួលជូនកម្មករនិយោជិត និយោជកបានគិតដោយបូករួមទាំងប្រាក់ធ្វើការបន្ថែមម៉ោង ហេតុនេះ កម្មករនិយោជិតពិបាកនឹងដឹងថា តើប្រាក់ឈ្នួលដែលពួកគាត់ធ្វើការចំនួន ៨ ម៉ោងនោះបាន ទទួលពិតប្រាកដចំនួនប៉ុន្មាន។
- ការកំណត់ចេញតម្លៃឡូត៍ គឺនិយោជកពឹងផ្អែកទៅលើការបញ្ជាទិញពីភ្ញៀវ។ និយោជកធ្វើការចាត់ចែង ទៅឱ្យកម្មករនិយោជិតដេរ ផ្អែកលើតម្លៃដែលភ្ញៀវដាក់ជូន។ បើផ្នែកណាដេរពិបាក និយោជកនឹងគិត តម្លៃឡូត៍នោះឱ្យច្រើនបន្តិច។ ជាទូទៅតម្លៃឡូត៍និមួយៗពុំសូវខុសគ្នាប៉ុន្មានទេ តួយ៉ាងដូចជាតម្លៃឡូត៍ លេខ ២០១៣៩ មានតម្លៃ ០.៥០ ដុល្លារអាមេរិកសម្រាប់ចំនួន ១០០ ឡូត៍។ ចំណែកឯតម្លៃឡូត៍លេខ ២០១៣៩ មានតម្លៃ ០.៩ ដុល្លារអាមេរិកសម្រាប់ ១០០ ឡូត៍។
- ការកំណត់ចេញតម្លៃឡូត៍កន្លងមក និយោជកពុំបានឱ្យកម្មករនិយោជិតដេរសាកល្បងជាមុនទេ។
- ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទាឱ្យក្រុមហ៊ុនតម្លើងតម្លៃបុងបន្ថែមចំនួន ០.២០ ដុល្លារអាមេរិក ជូនកម្មករនិយោជិតគ្រប់ផ្នែកទាំងអស់។ មូលហេតុដែលទាមទារនោះ គឺដោយសារតែកម្មករនិយោជិត ដែលធ្វើការដេរស៊ីបុងមួយចំនួនធំពុំអាចទទួលបានប្រាក់ឈ្នួលអប្បបរមាទេ ព្រោះដោយសារតម្លៃបុង ដែលនិយោជកគិតជូននោះទាបពេក និងម្យ៉ាងទៀត តម្លៃបុងដែលនិយោជកធ្លាប់គិតជូននោះ កាលពី ប្រាក់ឈ្នួលរបស់ពួកគាត់ចំនួន ៥០ ដុល្លារអាមរិកក្នុងមួយខែ ពួកគាត់អាចទទួលបានប្រាក់ឈ្នួល អប្បបរមាបានខ្លះ ប៉ុន្តែ បន្ទាប់ពីក្រសួងតម្លើងប្រាក់ឈ្នួលជូនពួកគាត់ចំនួន ៦១ ដុល្លារអាមរិកមក ពួក គាត់ពុំទទួលបានប្រាក់ឈ្នួលអប្បបរមាទេ។
- ភាគីនិយោជក បានលើកឡើងថា ជាមធ្យមមានកម្មករនិយោជិតដែលធ្វើការរួមទាំងម៉ោងបន្ថែមនោះ ចំនួន ២០ ភាគរយ ដែលពុំទទួលបានប្រាក់ឈ្នួលអប្បបរមា ដូចនេះ និយោជកបានបន្ថែមឱ្យគ្រប់ប្រាក់ ឈ្នួលអប្បបរមាចំនួន ៦១ ដុល្លារអាមេរិក។ ចំពោះមូលហេតុ គឺបណ្តាលមកពីកម្មករឈប់ច្រើន និង មានកម្មករចូលថ្មី។
- តាមរយៈរបាយការណ៍ប្រាក់បៀវត្សរ៍ដែលផ្តល់ដោយភាគីនិយោជក នៅក្នុងខែឧសភា មិថុនា និងកក្កដា ឆ្នាំ២០១១ ដែលជាខែសំបូរការងារធ្វើជាធម្មតានោះ បានបង្ហាញថា កម្មករនិយោជិតដែលដេរស៊ីបុងភាគ ច្រើនពុំសូវទទួលបានប្រាក់ឈ្នួលអប្បបរមាទេ ដោយបូករួមទាំងប្រាក់បន្ថែមម៉ោងផង។

ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារក្រុមហ៊ុនឱ្យតម្លើងលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ចំពោះការថែមម៉ោងដល់ម៉ោង ២០:០០ នាទី

- កម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោងពីម៉ោង ៤:០០ ដល់ម៉ោង ៦:០០ ល្ងាច ពួកគាត់ទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ រៀល។
- ក្នុងករណីនេះ បើកម្មករនិយោជិតស្ម័គ្រចិត្តធ្វើការបន្តពីម៉ោង ៦:០០ ដល់ម៉ោង ៨:០០ យប់ ពួកគាត់សុំឱ្យនិយោជកបន្ថែមលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ផ្សេងទៀត។ មូលហេតុ គឺថាច្បាប់តម្រូវឱ្យធ្វើការតែចំនួន ១០ ម៉ោងទេ ក្នុងមួយថ្ងៃ និងម្យ៉ាងទៀតសេចក្តីជូនដំណឹងរបស់ក្រសួងស្តីពីប្រាក់ថ្លៃបាយចំនួន ២០០០ រៀល។ ទន្ទឹមនឹងនេះដែរ កម្មករនិយោជិតមានជីវភាពខ្វះខាតខ្លាំង និងប្រឈមទៅនឹងការរងគ្រោះថ្នាក់ផ្សេងៗ ដូចជាបញ្ហាសុខភាពជាដើម ដោយសារតែការធ្វើការថែមម៉ោងច្រើន។
- ភាគីនិយោជកពុំអាចជូនតាមសំណូមពរបានទេ។ ហើយមូលហេតុ គឺនិយោជកពុំមានលទ្ធភាព និងម្យ៉ាងទៀតការថែមម៉ោង គឺឈរលើគោលការណ៍ស្ម័គ្រចិត្ត។

ចំណុចវិវាទទី៣ ៖ កម្មករនិយោជិតទាមទារក្រុមហ៊ុនឱ្យតម្លើងប្រាក់ឈ្នួលគោលដល់ជំនួយការក្រុមផ្នែកបើកកាវ៉ាន់ចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ

- នៅក្នុងក្រុមហ៊ុនមានក្រុមដេរចំនួន ៩ ក្រុម ហើយក្រុមនីមួយៗមានជំនួយការក្រុមចំនួន ២ នាក់។
- ប្រាក់ឈ្នួលរបស់កម្មករ ដែលជាជំនួយការក្រុមមានចំនួន ៦១ ដុល្លារអាមេរិក ក្នុងមួយខែ។
- ការងាររបស់ជំនួយការក្រុមមានដូចជា ស្រង់វត្តមានកម្មករនៅក្នុងក្រុម បើកខោ រាប់ផ្លាក រាប់កៅស៊ូរ៉ូតយកខោទៅបង្ហើយការ បើកអំបោះ និងបើកលុយបាយប្រចាំសប្តាហ៍ជាដើម។
- តាមរបាយការណ៍ដែលផ្តល់ដោយភាគីកម្មករនិយោជិតបានលើកឡើងថា ពួកគាត់ទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនដល់កម្មករនិយោជិតចំនួន ១២ នាក់ ដែលជាជំនួយការក្រុមឱ្យបានគ្រប់ចំនួន ៧០ ដុល្លារអាមេរិកក្នុងមួយខែ ដោយយោងតាមមាត្រា ១០៦. ១០៧ និង១២ នៃច្បាប់ស្តីពីការងារ។
- ភាគីនិយោជកពុំអាចផ្តល់ជូនតាមសំណូមពរទេ ព្រោះក្រុមហ៊ុនពុំមានលទ្ធភាព ហើយម្យ៉ាងទៀតក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតទៅតាមជំនាញ និងសមត្ថភាពរបស់ពួកគាត់។

## ហេតុផលនៃសេចក្តីសម្រេច ៖

ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងតម្លៃបុងបន្ថែមចំនួន ០.២០ ដុល្លារអាមេរិក ជូនកម្មករនិយោជិតគ្រប់ផ្នែកទាំងអស់

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬ អនុសញ្ញារួមណាមួយចែងពីការទាមទារនោះ"។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ហ្គូលកាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ។ ការទាមទារក្នុងចំណុចនេះ គឺទាក់ទងនឹងអាត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតតាមបរិមាណផលិតផល ហេតុនេះចំណុចវិវាទនេះជាចំណុចវិវាទអំពីសិទ្ធិ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាការទាមទារដូចខាងក្រោមនេះ ៖

មាត្រា ១០៨ នៃច្បាប់ស្តីពីការងារ ចែងថា "*ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ទោះធ្វើនៅរោងជាង ឬនៅលំនៅក៏ដោយ ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិត ដែលមានការប៉ិនប្រសប់មធ្យម ធ្វើការជាធម្មតាបានទទួលក្នុងថិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិត។*"

ចំណុច៣ នៃសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/សជណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ចែងថា "*៣-ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួល ដែលបានចែងក្នុងចំណុចទី២ខាងលើត្រូវទទួលបានតាមការលើសនោះ។*"

សេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣/០៥-ហ្វាហ៊ីង ជ្រាហ៊ុង ចំណុចវិវាទទី៦ បានបកស្រាយថា "*ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា មាត្រា ១០៨ ផ្តល់មូលដ្ឋានសម្រាប់ការគណនាកំណត់តម្លៃឡូត៍តាមច្បាប់ការងារ គឺតម្លៃឡូត៍ត្រូវអនុញ្ញាតឱ្យកម្មករដែលមានជំនាញជាមធ្យមអាចធ្វើការតាមម៉ោងធម្មតា ៨ ម៉ោងក្នុង មួយថ្ងៃ (៤៨ ម៉ោង ក្នុងមួយសប្តាហ៍) អាចទទួលបានយ៉ាងហោចណាស់ប្រាក់ឈ្នួលអប្បបរមា...*"

*នៅក្នុងសំណុំរឿងមុនៗទាក់ទងនឹងតម្លៃឡូត៍ ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការពិនិត្យទៅលើកត្តា ២ ដើម្បីកំណត់ថា តម្លៃឡូត៍នោះត្រឹមត្រូវ (ទី១)-ក្រុមហ៊ុនត្រូវឱ្យកម្មករនិយោជិតធ្វើសាកល្បងជាមុនសិនមុននឹងកំណត់តម្លៃឡូត៍ និង(ទី២)-លទ្ធផលជាក់ស្តែងទាក់ទងនឹងប្រាក់ឈ្នួល ក្រោយពេលតម្លៃឡូត៍ត្រូវបានកំណត់។(សូមមើលសេចក្តីបង្គាប់លេខ ០៣/០៥-នាគហោះ ហេតុផលនៃចំណុចវិវាទទី៦, លេខ ១១/០៦- ហ្វូឡូន ហេតុផលនៃចំណុចវិវាទទី១ លេខ ៤៤/០៧- វិនណឺ ណៃធីង ហ្វាក់តូរី ហេតុផលចំណុចវិវាទទី១ )*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏យល់ស្របទៅតាមការលើកឡើងនេះដែរ។

តាមរយៈអង្គហេតុ ការកំណត់ចេញតម្លៃឡូត៍ គឺនិយោជកពឹងផ្អែកទៅលើការបញ្ជាទិញបន្តពីភ្ញៀវ ដោយនិយោជក ធ្វើការចាត់ចែងទៅឱ្យកម្មករនិយោជិតដេរ ផ្អែកលើតម្លៃដែលភ្ញៀវដាក់ជូន។ បើផ្នែកណាដែលដេរពិបាកនិយោជកនឹងគិតតម្លៃឡូត៍នោះឱ្យច្រើនបន្តិច។ ក្នុងករណីនេះ និយោជកពុំបានឱ្យកម្មករដេរសាកល្បងទេ គឺកំណត់តម្លៃឡូត៍ដោយឯកតោភាគីតែម្តង។ ហើយបើក្នុងករណីដែលកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់

ឈ្នួលអប្បបរមាចំនួន ៦១ ដុល្លារអាមេរិកក្នុងមួយខែ នោះនិយោជកនឹងបន្ថែមឱ្យគ្រប់ចំនួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា តាមរយៈរបាយការណ៍ប្រាក់បៀវត្សរ៍ដែលផ្តល់ដោយភាគីនិយោជក នៅក្នុង ខែឧសភា ខែមិថុនា និងខែកក្កដា ឆ្នាំ២០១១ ដែលជាខែសំបូរការងារធ្វើជាធម្មតានោះ បានបង្ហាញថា កម្មករនិយោជិតដែលដេរស៊ីបុងភាគច្រើនពុំសូវទទួលបានដល់ប្រាក់ឈ្នួលអប្បបរមាទេ (ដោយបូករួមទាំងប្រាក់បន្ថែមម៉ោងផង)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា ការកំណត់តម្លៃឡូត៍ដោយផ្អែកលើតម្លៃដែលភ្ញៀវដាក់ជូន និងធ្វើការចាត់ចែងទៅឱ្យកម្មករនិយោជិតដេរតែម្តងពុំទាន់ត្រឹមត្រូវទេ។ ការកំណត់បែបនេះ ធ្វើឱ្យប៉ះពាល់ទៅដល់អាត្រាប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងម្យ៉ាងទៀតមិនអាចកំណត់បានថា តើកម្មករនិយោជិតភាគច្រើន ជាពិសេសកម្មករនិយោជិតដែលមានជំនាញជាមធ្យមអាចទទួលបាននូវប្រាក់ឈ្នួលអប្បបរមាបាន ឬទេ?។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវរៀបចំឱ្យកម្មករនិយោជិតដេរសាកល្បងជាមុនសិន មុននឹងសម្រេចកំណត់តម្លៃឡូត៍ ដើម្បីឱ្យដឹងថា តើកម្មករនិយោជិតដែលមានជំនាញមធ្យមអាចដេរបានប្រាក់ឈ្នួលជាមធ្យមប៉ុន្មាន។ ហើយនិយោជកត្រូវរកវិធីសាស្ត្រដ៏សមរម្យក្នុងការកំណត់ជំនាញ និងសមត្ថភាពរបស់កម្មករនិយោជិត គឺនិយោជកត្រូវធ្វើការសាកល្បងមួយ ដោយប្រើកម្មករនិយោជិតដែលមានជំនាញផ្សេងៗគ្នា (យឺត មធ្យម និងលឿន)។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា កម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលពួកគាត់ធ្វើបាន ប៉ុន្តែទោះ ជាយ៉ាងណាការគិតប្រាក់ឈ្នួលតាមបរិមាណផលិតផលនេះ គឺមានបំណងឱ្យកម្មករនិយោជិតខិតខំធ្វើការ ដើម្បីឱ្យពួកគាត់ទទួលបានប្រាក់ឈ្នួលច្រើនជាងប្រាក់ឈ្នួលអប្បបរមា។ បើក្នុងករណី កម្មករនិយោជិតខិតខំធ្វើការហើយ ហើយពួកគាត់នៅតែទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមាទៀតនោះ ការកំណត់តម្លៃឡូត៍នោះអាចមានបញ្ហា ដូចនេះ និយោជកត្រូវពិចារណាការកំណត់តម្លៃឡូត៍នេះ ឡើងវិញ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកតម្លើងតម្លៃបុងបន្ថែមចំនួន ០.២០ ដុល្លារអាមេរិក ជូនលើភីអូទាំងអស់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា ការសុំតម្លើង ចំនួន ០.២០ ដុល្លារអាមេរិក ពុំដឹងថា វាអាចឱ្យកម្មករនិយោជិតដែរមានជំនាញជាមធ្យម ធ្វើបានយ៉ាងហោចណាស់ស្មើរនឹងប្រាក់ឈ្នួលអប្បបរមា ឬទាបជាងប្រាក់ឈ្នួលអប្បរមាដែរឬទេ។ ហេតុនេះ ការកំណត់តម្លៃជាក់លាក់ដោយមិនមានការដេរសាកល្បង គឺមិនមែនជាជំរើសដ៏ត្រឹមត្រូវនោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកតម្លើងតម្លៃបុងបន្ថែមចំនួន ០.២០ ដុល្លារអាមេរិក ជូនលើភីអូទាំងអស់ និងបង្គាប់ឱ្យនិយោជកត្រៀបចំឱ្យកម្មករនិយោជិតដេរសាកល្បងជាមុនសិន មុននឹងសម្រេចកំណត់តម្លៃឡូត៍ ដែលត្រូវធានាថា តម្លៃឡូត៍ដែលនិយោជកផ្តល់ជូននេះមិនទាបជាងប្រាក់ឈ្នួលអប្បបរិមាបច្ចុប្បន្ន។

ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារក្រុមហ៊ុនឱ្យតម្លើងលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ចំពោះការថែមម៉ោងពីម៉ោង០៦:០០ដល់ម៉ោង ០៨:០០នាទី យប់

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាដូចខាងក្រោម ៖

សេចក្តីជូនដំណឹងលេខ ០៤១/១១ ស.ប/សជណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណុចទី២ ចែងថា ៖

២." *កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយ ចំនួន ២.០០០ (ពីរពាន់)រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយ ពេលដោយឥតគិតថ្លៃ ។"*

*៤.ចំណុចទី៤ នៃសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៤៩/១០ បក/សជណ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០ត្រូវចាត់ទុកនិរាករណ៍ ។"*

ខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ បានកំណត់យ៉ាងច្បាស់ថា ថ្លៃបាយសម្រាប់ការធ្វើការបន្ថែមម៉ោងចំនួន ២.០០០ រៀល គឺឈរលើមូលដ្ឋាន "ក្នុងមួយថ្ងៃ" ដោយមិនកំណត់ថា ប៉ុន្មានម៉ោងទេ ។

ក្នុងករណីនេះ និយោជកផ្តល់ប្រាក់ថ្លៃបាយចំនួន ២.០០០ រៀល ចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការថែមម៉ោងពីម៉ោង ៤:០០ រសៀល ដល់ម៉ោង ៦:០០ នាទីល្ងាច ប៉ុន្តែបើកកម្មករនិយោជិតបន្តធ្វើការបន្ថែមម៉ោងនេះពីម៉ោង៦:០០ រហូតដល់ម៉ោង ៨:០០ នាទី យប់ និយោជកពុំបានផ្តល់ជូនទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា និយោជកបានគោរព និងអនុវត្តតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ស.ប/សជណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ រួចហើយ ដោយផ្តល់ប្រាក់ថ្លៃបាយសម្រាប់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងនេះ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតខាងលើ គឺជាការទាមទារដែលពាក់ព័ន្ធនឹងផលប្រយោជន៍លើសអ្វីដែលច្បាប់ស្តីពីការងារបានកំណត់ពោលគឺវិវាទនេះគឺជាវិវាទអំពីប្រយោជន៍ ។

ជាទូទៅ ចំពោះវិវាទអំពីប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចទទួលដោះស្រាយបានលុះត្រាតែសហជីពដែលលើកយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុត ។ *(សូមមើលសេចក្តីបង្គាប់លេខ ១៥/១១-ហ្គោលដេន ហ្គេន ស៊ូ ហេតុផលចំណុចវិវាទទី១)* ។

ក្នុងករណីនេះ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា មិនមានភាពជាតំណាងបំផុតក្នុងរោងចក្រទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនពិចារណាលើចំណុចនៃវិវាទនេះទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនតម្លើងលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ចំពោះការថែមម៉ោងពីម៉ោង ០៦:០០ ដល់ម៉ោង ០៨:០០ នាទី យប់ ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី៣ ៖ កម្មករនិយោជិតទាមទារក្រុមហ៊ុនឱ្យតម្លើងប្រាក់ឈ្នួលគោលដល់ជំនួយការក្រុមផ្នែកបើកឥវ៉ាន់ចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ

កម្មករនិយោជិតទាមទារឱ្យនិយោជកតំឡើងប្រាក់ឈ្នួលគោលចំនួន ៩ ដុល្លារអាមេរិក បន្ថែមលើប្រាក់ឈ្នួលគោលដែលក្រុមហ៊ុនធ្លាប់ផ្តល់ជូន ៦១ ដុល្លារអាមេរិក ក្នុងមួយខែ ជូនដល់ជំនួយការក្រុមទាំងអស់ដែលមានចំនួន ១២ នាក់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកត្រូវមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតដែលជាជំនួយការក្រុមទាំងអស់ដែលមានចំនួន ១២ នាក់ ដែរ ឬទេ ?

ចំណុច ២ នៃសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/សជណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ចែងថា *"...កម្មករនិយោជិតដែលពេញសិទ្ធិ ត្រូវទទួលប្រាក់ឈ្នួលអប្បបរមាចំនួន ៦១ (ហុកសិបមួយ) ដុល្លារអាមេរិក ក្នុងមួយខែ..."* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីជូនដំណឹងនេះ គឺបានធានាប្រាក់ឈ្នួលអប្បបរមាចំនួន ៦១ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិតទូទៅ គឺមិនបានបង្ហាញអំពីការផ្តល់ជូនទាក់ទងទៅនឹងកម្មករនិយោជិតដែលជាជំនួយការក្រុមដែលត្រូវទទួលខុសត្រូវនូវការងារជាច្រើនទេ ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា កម្មករនិយោជិត ដែលទទួលបានប្រាក់ឈ្នួលអប្បរមាចំនួន ៦១ ដុល្លារអាមេរិក ក្នុង១ខែ គឺស្របទៅតាមសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/សជណ រួចហើយ ។

ទន្ទឹមនឹងនេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទបញ្ញត្តិនៃច្បាប់ការងារណាចែងអំពីការតំឡើងជូនប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលជាជំនួយការក្រុមទេ ហើយម្យ៉ាងទៀត ភាគីនិយោជក និងកម្មករនិយោជិតក៏ពុំមានបានធ្វើកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយដែលចែងអំពីការផ្តល់ជូនប្រាក់ឈ្នួលគោលចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែដែរ។ ដូច្នេះការទាមទាររបស់កម្មករនិយោជិត មានលក្ខណៈជាការទាមទារបែបផលប្រយោជន៍ ។

ជាទូទៅ ចំពោះវិវាទអំពីប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចទទួលដោះស្រាយបានលុះត្រាតែសហជីពដែលលើកយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុត។ (*សូមមើលហេតុផលនៃសេចក្តីសម្រេចវិវាទអំពីផលប្រយោជន៍ ចំណុចទី ២ ខាងលើ*)។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនដល់កម្មករនិយោជិតចំនួន ១២ នាក់ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទារឱ្យនិយោជកតម្លើងតម្លៃបុងបន្ថែម ចំនួន ០.២០ ដុល្លារអាមេរិក ជូនកម្មករនិយោជិតគ្រប់ផ្នែកទាំងអស់។
- បង្គាប់ឱ្យនិយោជករៀបចំឱ្យកម្មករនិយោជិតដេរសាកល្បងជាមុនសិន មុននឹងសម្រេចកំណត់តម្លៃឡូត៍ ដែលត្រូវធានាថា តម្លៃឡូត៍ដែលនិយោជកផ្តល់ជូននេះ មិនទាបជាងប្រាក់ឈ្នួលអប្បបរិមាបច្ចុប្បន្ន។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០។*

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖**

**ចំណុចវិវាទទី ២ ៖**

បដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនតម្លើងលុយថ្លៃបាយបន្ថែមចំនួន ៣០០០ រៀល ចំពោះការថែមម៉ោងពីម៉ោង ០៦:០០ ដល់ម៉ោង ០៨:០០ នាទី យប់។

**ចំណុចវិវាទទី ៣ ៖**

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនដល់កម្មករនិយោជិតចំនួន ១២ នាក់។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទូន ស៊ីផាន់**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន មុំនិឃា**

ហត្ថលេខា: --------------------------------